សហភាពអឺរ៉ុប  កម្មវិធីស្បៀងអាហារ

FAO EU Food Facility Project

# បច្ចេកទេសក្នុងការទុកដាក់ស្រូវពូជ






ធុងដាក់គ្រាប់ពូជស្រូវ

- ធុងត្រូវស្អាត និងស្ងួតមុនពេលដាក់ស្រូវ
- សំណើមគ្រាប់ស្រូវ ១១-១២ %
- រក្សាទុកធុងនៅកន្លែងម្លប់
- កម្តៅលើគ្រាប់ស្រូវពេលហាលកុំឱ្យលើសពី ៤៣ អង្សាសេ ព្រោះវាធ្វើឱ្យគ្រាប់ពូជស្រូវមាន ដំណុះខ្សោយ ឬ មិនដុះ។

## ១. ការទុកដាក់ស្រូវពូជតាមទម្លាប់

ជាទូទៅ កសិករទម្លាប់ទុកដាក់គ្រាប់ពូជស្រូវក្នុងបាវ ដែលមានចំណុះចាប់ពី ៤០ ទៅ ១០០ គីឡូក្រាម ដោយដាក់នៅក្នុងផ្ទះក្បែរសរសរ ឬ ជិតមាត់ទ្វារខាងមុខ ឬ ដាក់ក្នុងជង្រុក ដែលដាក់ស្រូវចំណី។



ការទុកដាក់ស្រូវពូជក្នុងបាវ រួចដាក់ក្បែរសរសរក្នុងផ្ទះ



ការទុកដាក់ស្រូវពូជក្នុងបាវ រួចដាក់ក្នុងជង្រុក

### គុណវិបត្តិនៃការទុកដាក់ស្រូវពូជតាមទម្លាប់

- អត្រាសំណើមគ្រាប់ស្រូវ ងាយនឹងឡើងចុះទៅតាមការប្រែប្រួលនៃសំណើមបរិយាកាស
- ងាយរងការបំផ្លាញពីសត្វល្អិត កណ្ដុរ សត្វស្លាប និង មានជម្ងឺផ្សិត
- អត្រាដំណុះទាប (ប្រើប្រាស់ពូជច្រើន)។